# លទ្ធផលការងាររៀបចំដែនដី និងនគរូបនីយកម្ម
# ផែនការរៀបចំដែនដីថ្នាក់រាជធានី ខេត្តដែលបានអនុម័តរួច

## ១.ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

រាជធានីភ្នំពេញចែកចេញជា ១២ ខណ្ឌ និង ៩៦ សង្កាត់ មានក្រឡាផ្ទៃដីសរុបប្រមាណ ៦៧៨,៤៧ គីឡូម៉ែត្រក្រឡា និងមានប្រជាជនប្រមាណ ២.០០០.០០០ នាក់ ។

ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ ២០៣៥ បានសម្រេចដាក់ឱ្យអនុវត្តន៍តាម អនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១៥ ។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញនេះគឺ ភ្នំពេញជាទីក្រុង រាជធានី ជាបេះដូងរបស់ប្រទេសកម្ពុជា ដែលស្ថិតនៅលើចំណុចពិសេសនៃប្រសព្វទន្លេបួន ហៅថា ទន្លេបួនមុខ ដែលជាអត្តសញ្ញាណតែមួយគ្មានពីរ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្តានុពលប្រកួតប្រជែងជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចិរភាព ។



## ២.ផែនការរៀបចំដែនដីខេត្តព្រះសីហនុ

ខេត្តព្រះសីហនុចែកជា ៣ ស្រុក និង ១ ក្រុង មានក្រឡាផ្ទៃដីសរុបប្រមាណ ២៤៧៩,៥៦ គីឡូម៉ែត្រក្រឡា និងមានប្រជាជនប្រមាណ ៣០០.០០០ នាក់ ។

ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ ២០៣០ បានសម្រេចដាក់ឱ្យអនុវត្តន៍តាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៨ ។

ចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តព្រះសីហនុគឺរៀបចំ និងអភិវឌ្ឍ “ ខេត្តព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រ ដែលស្អាតបំផុតលើសកលលោក តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាន និងទីផ្សារសកលលោក និងមជ្ឈមណ្ឌលឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ ” ដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា និងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយជាតិស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗ ជាច្រើនទៀតរបស់រាជរដ្ឋាភិបាល។



## ៣.ផែនការរៀបចំដែនដីខេត្តបាត់ដំបង

ខេត្តបាត់ដំបងចែកជា ៧ ស្រុក ១ ក្រុង និង ៩៣ ឃុំ សង្កាត់ មានក្រឡាផ្ទៃដីសរុបប្រមាណ ១១ ៧៤៨ គីឡូម៉ែត្រក្រឡា និងមានប្រជាជនប្រមាណ ១ ២៨៣ ២២៣ នាក់ ។

ផែនការរៀបចំដែនដីខេត្តបាត់ដំបងមានចក្ខុវិស័យឆ្នាំ ២០៣០ បានសម្រេចដាក់ឱ្យអនុវត្តន៍តាមអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៨ ។

ផែនការរៀបចំដែនដីខេត្តបាត់ដំបងមានចក្ខុវិស័យឆ្នាំ ២០៣០ គឺសំដៅរៀបចំ និងអភិវឌ្ឍ“ខេត្តបាត់ដំបងជាតំបន់ស្នូលសេដ្ឋកិច្ចភាគពាយ័ព្យនៃប្រទេសកម្ពុជា” តាមរយៈការជំរុញរៀបចំ និងអភិវឌ្ឍជា÷

- តំបន់ស្នូលនគរូបនីយកម្ម អភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សកាន់តែប្រសើរឡើង
- តំបន់ផលិតផលកសិកម្មប្រកបដោយគុណភាពខ្ពស់
- មជ្ឈមណ្ឌលពាណិជ្ជកម្ម និងឧស្សាហកម្មកែច្នៃផលិតផលកសិកម្មប្រកបដោយការប្រកួតប្រជែង
- តំបន់ទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- តំបន់សមាហរណកម្មចម្រុះរវាងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងធនធានធម្មជាតិ។

